កូន មាស ថ្មី ពុក

ភ្លេចអ្វីភ្លេចបាន តែបើភ្លេចប្រាណ ធ្លាក់ចូលរណ្តៅ
បើបានជាធ្លាក់ មិនទាន់ធ្លាក់ជ្រៅ ប្រឹងឡើងណាពៅ
កុំនៅនាំជ្រុល ។

ខូចអ្វីមិនគ្រោះ តែបើខូចឈ្មោះ មិនងាយជួសជុល
កូនត្រូវប្រយ័ត្ន កុំងប់ងងុល កាមជាគ្រឿងពុល
ខូចអស់ទាំងខ្លួន ។

ខូចខ្លួនខូចឈ្មោះ ខូចនេះពេញគ្រោះ សៅលែងសិប់សួន
តែទោះយ៉ាងណា កុំឲ្យខូចផ្ទួន ត្រូវប្រឹងកែខ្លួន
កុំចោលអាត្មា ។

ចោលអ្វីចោលបាន តែកុំចោលប្រាណ ក្នុងវដ្តសង្សារ
ព្រោះក្នុងលោកនេះ ឥតមាននរណា ជួយស្រង់អាត្មា
ក្រៅពីខ្លួនឡើយ ។

កូនត្រូវរក្សា ការពារអាត្មា ឲ្យបានដល់ត្រើយ
ដោយការប្រយ័ត្ន នឹងមិនកន្តើយ ប្រយ័ត្នហ្នឹងហើយ
ជាព្រះក្នុងខ្លួន ។

ប្រយ័ត្នជាម្តាយ ញុាំងគុណទាំងឡាយ ឲ្យកើតមាំមួន
អត់ធន់ជាទី រក្សាគ្រងស្លួន គុណធម៌ក្នុងខ្លួន
ដូចខែខាងខ្នើត ។

ខន្តីដូចថ្នាំ លេបជាប្រចាំ រសជាតិល្វីងចេត
លំបាកទ្រាំណាស់ លុះដល់ផលកើត រសជាតិល្វីងចេត
មានគុណគាប់ហោង ។

ដោយ ប៊ុត សាវង្ស